**ឯកសារស្រាវជ្រាវ**

លេខាធិការដ្ឋានអ្នកនាំពាក្យព្រឹទ្ធសភា

# ការពង្រឹងមុខងារតំណាងរបស់សភានៅកម្ពុជា


ស្រាវជ្រាវដោយ៖ បណ្ឌិត **ថេល័រ ជេន**
ដោយមានការចូលរួមពី៖ លោកស្រី **ជា ម៉ាលីកា**
ផ្តល់យោបល់ដោយ៖ លោក **យុត ឥន្ទសេរី**



ខែតុលា ២០១៥
**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាឲ្យបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)

# មាតិកា


១. សេចក្តីផ្តើម ........................................................ 1

១.១ វិធានការណ៍ដើម្បីជួយដល់អ្នកសារព័ត៌មាន ........................................ 2

២. តម្រូវការដែលបានលើកឡើងសម្រាប់ការពង្រឹងសមត្ថភាព ........................................ 6

៣. ការពង្រឹងជំនាញទំនាក់ទំនងសមាជិកសភាក្នុងការគាំទ្រនូវមុខងារជាតំណាង ........................................ 7

៣.១ យុទ្ធសាស្រ្តនៃទំនាក់ទំនង និងផែនការផ្សារភ្ជាប់ ........................................ 7

៣.២ បណ្តាញសង្គម ........................................ 8

៣.៣ យុទ្ធនាការផ្សព្វផ្សាយសង្គម (ព័ត៌មានសាធារណៈ) ........................................ 10

៣.៤ ជំនាញក្នុងការនិយាយ ........................................ 11

៤. តើសមាជិកសភាអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពង្រឹងតួនាទីភាពជាតំណាងយ៉ាងដូចម្តេច? 12

៤.១ ការយល់អំពីអ្វីដែលធ្វើឲ្យអត្ថបទព័ត៌មានមួយ «ល្អ» ........................................ 13

៤.២ ដោះស្រាយការសម្ភាសន៍តាមប្រព័ន្ធសារព័ត៌មាន ដោយឆ្លើយនឹងសំណួរពិបាកៗ និងដោះស្រាយវិបត្តិផ្សេងៗ ........................................ 14

៥. សេចក្តីសន្និដ្ឋាន ........................................ 15

ឯកសារយោង ........................................ 17

# ១. សេចក្តីផ្តើម

ព្រឹទ្ធសភាមានតួនាទីបីសំខាន់ៗ ភាពជាតំណាង តាក់តែងច្បាប់ និងត្រួតពិនិត្យ។ នៅក្នុងការអនុវត្តមុខងារខុសៗគ្នារបស់ខ្លួននេះ រដ្ឋបាលរបស់ព្រឹទ្ធសភាមានភារកិច្ចកសាងព័ត៌មាន និងមធ្យោបាយទំនាក់ទំនងឲ្យបានល្អជាមួយប្រព័ន្ធផ្សព្វផ្សាយ ជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីផ្តល់នូវព័ត៌មានដែលត្រឹមត្រូវអំពីដំណើរការការងាររបស់ព្រឹទ្ធសភា។ ទាក់ទងទៅនឹងការងារនេះ ***លេខាធិការដ្ឋានអ្នកនាំពាក្យព្រឹទ្ធសភា*** ត្រូវបានបង្កើតឡើងដើម្បីពង្រឹងតម្លាភាពលើដំណើរការតាក់តែងច្បាប់របស់ព្រឹទ្ធសភា តាមរយៈការផ្តល់នូវព័ត៌មានថ្មីៗជាប្រចាំទៅឲ្យប្រព័ន្ធផ្សព្វផ្សាយ និងសាធារណៈជនទាក់ទងទៅនឹងសកម្មភាពនានារបស់ព្រឹទ្ធសភា ប្រកបដោយ ឯករាជ្យភាព និងអព្យាក្រឹត្យភាព។ អង្គភាពនេះក៏ជួយក្នុងការពង្រឹងការងារទំនាក់ទំនងជាមួយសាធារណៈជន តាមរយៈការផ្សព្វផ្សាយ និងរៀបចំដំណើរទស្សនាកិច្ចស្វែងយល់ពីសភា និងរៀបចំដើម្បីឲ្យសាធារណៈជន និងអ្នកសារព័ត៌មានអាចចូលមកដល់អគាររបស់ស្ថាប័នព្រឹទ្ធសភា និងបានចូលទៅស្តាប់កិច្ចប្រជុំពិសេស កិច្ចពិភាក្សា និងវេទិកាផ្សេងៗជាដើម។ បន្ថែមពីលើនេះទៀត អង្គភាពនេះក៏បានធ្វើការផ្តល់យោបល់ជូនសមាជិកសភាគ្រប់រូប មកពីគ្រប់គណបក្សនយោបាយ អំពីវិធីសាស្ត្រឆ្លើយតបទៅកាន់អ្នកបោះឆ្នោតរបស់ខ្លួន ដោយផ្តល់នូវព័ត៌មានដែលពាក់ព័ន្ធ តាមរយៈអង្គភាពទំនាក់ទំនងរបស់សភា (ដូចជា លេខាធិការដ្ឋានអ្នកនាំពាក្យព្រឹទ្ធសភាជាដើម)។[1] គោលបំណងនៃការបង្កើតអង្គភាពនេះគឺដោយសារតែព្រឹទ្ធសភាកម្ពុជាយល់ឃើញថា ព័ត៌មានអំពីកិច្ចការសភាត្រូវតែផ្សព្វផ្សាយទៅដល់ប្រព័ន្ធផ្សព្វផ្សាយ និងប្រជាពលរដ្ឋឲ្យកាន់តែទូលំទូលាយជាងមុន។

ឯកសារស្រាវជ្រាវនេះគឺជាឯកសារជំនួយសម្រាប់សិក្ខាសាលាដែលនឹងត្រូវរៀបចំនៅចុងឆ្នាំ ២០១៥ ខាងមុខនេះ។ គោលបំនងរបស់សិក្ខាសាលាគឺ ដើម្បីផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយអំពីការងារថ្មីៗ និងដើម្បីពង្រឹងការយល់ដឹងរបស់សមាជិកព្រឹទ្ធសភា និងអ្នកចូលរួមដទៃទៀតអំពីសារៈប្រយោជន៍នៃតួនាទីព័ត៌មាន និងការត្រួតពិនិត្យពីប្រព័ន្ធផ្សព្វផ្សាយតាមរយៈរបាយការណ៍ជាប្រចាំអំពីកិច្ចការរបស់សភា។

ឯកសារនេះនឹងផ្តោតលើការពង្រឹងតួនាទីជាតំណាងរបស់សមាជិកសភាតាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ ការស្រាវជ្រាវក៏នឹងលើកបង្ហាញពីតួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គមប្រជាធិបតេយ្យ ទំនាក់ទំនងរបស់សភានៅក្នុងប្រទេសកម្ពុជា និងការអនុវត្តន៍របស់ប្រទេសដទៃទៀត ថាតើអ្វីដែលធ្វើឲ្យខ្លឹមសារព័ត៌មាននោះ «ល្អ» យន្តការ និង

1 Senate Spokesman Secretariat, 2014, *Structure and Role of Senate Spokesman Secretariat*, p 1-5.

វិធីសាស្រ្តក្នុងការចែករំលែកព័ត៌មាន និងវិធីសាស្រ្តដែលសមាជិកសភាអាចទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មានប្រកបដោយប្រសិទ្ធភាព។

## ១.១ វិធានការណ៍ដើម្បីជួយដល់អ្នកសារព័ត៌មាន

មាត្រា៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានបញ្ជាក់ពីតួនាទីដ៏សំខាន់របស់ប្រព័ន្ធផ្សព្វផ្សាយនៅដំណើរការលទ្ធិប្រជាធិប-តេយ្យ ដូចជា ការផ្តល់ឲ្យនូវវេទិកាមួយដែលប្រជាពលរដ្ឋអាចបញ្ចេញ និងពិភាក្សាវែកញែកទៅលើទស្សនៈផ្ទាល់ខ្លួន ហើយជាទីកន្លែងដែលព័ត៌មានស្តីពីការតាក់តែងច្បាប់ កិច្ចការសភា និងការបោះឆ្នោតត្រូវបានចែករំលែក ហើយដែលប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលអាចផ្សារភ្ជាប់គ្នា៖ វិជ្ជាជីវៈរបស់ប្រព័ន្ធផ្សព្វផ្សាយគួរតែមានសិទ្ធិសេរីភាពក្នុងការពាំនាំនូវព័ត៌មានដែលពាក់ព័ន្ធ[2] ដែលមានការគាំទ្រពីច្បាប់សារព័ត៌មានឆ្នាំ១៩៩៥។[3] ទោះជាយ៉ាងណាក្តី ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសកម្ពុជានៅតែជួបបញ្ហាប្រឈម។[4] លោក ចូរជិន ហាមប័រម៉ាស[5] និងអ្នកមួយចំនួនទៀតយល់ឃើញថា ប្រព័ន្ធផ្សព្វផ្សាយបង្កើតបរិយាកាសសាធារណៈមួយសម្រាប់វេទិកានយោបាយ ប៉ុន្តែដើម្បីបំពេញមុខងារនេះឲ្យបានពេញលេញ អ្នកដែលមានអំណាចទាំងឡាយ ក៏ដូចជាអ្នកសារព័ត៌មាននៅក្នុងប្រទេសត្រូវតែទទួលស្គាល់ពីសារៈសំខាន់របស់ប្រព័ន្ធផ្សព្វផ្សាយ និងមធ្យោបាយដែលអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយផ្លែផ្កា និងការទទួលខុសត្រូវ។ ការងារនេះត្រូវការចំនុចសំខាន់ពីរដែលបច្ចុប្បន្ននេះកម្ពុជានៅមិនទាន់មានភាពរឹងមាំទៅលើចំនុចនេះនៅឡើយទេ។

ចំនុចដំបូងគឺប្រព័ន្ធផ្សព្វផ្សាយត្រូវការមានសេរីភាពគ្រប់គ្រាន់ ដើម្បីដើរតួនាទីជាអ្នកពាំនាំសារដែលប្រជាពលរដ្ឋអាចទុកចិត្ត និងប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីធ្វើការសម្រេចចិត្តទៅលើបញ្ហាដែលពាក់ព័ន្ធនឹងការបោះឆ្នោត (គួរចូលរួមបោះឆ្នោតឬអត់ គួរបោះឆ្នោតឲ្យភាគីណា តើភាគីនោះអាចទុកចិត្តបានប៉ុណ្ណា)។ សេរីភាពសារព័ត៌មានត្រូវតែដើរទន្ទឹមគ្នាជាមួយនឹងស្មារតីទទួលខុសត្រូវក្នុងនាមខ្លួនជាអ្នកសារព័ត៌មាន ព្រមជាមួយនឹងការយល់ដឹង និងការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈនៅពេលដែលអនុវត្តតួនាទីរបស់ខ្លួន។ ចំនុចនេះនឹងត្រូវពិភាក្សានៅកថាខ័ណ្ឌបន្ទាប់។ ទោះជាយ៉ាងណាក៏ដោយ បើយោងទៅតាមសន្ទស្សន៍ដែលចេញផ្សាយរៀងរាល់ឆ្នាំដោយ

---

[2] Cambodian Center for Human Rights, *Repression of Expression: The state of free speech in Cambodia* (CCHR, September, 2013), pp13, http://www.cchrcambodia.org/admin/media/report/report/english/2013_09_19_CCHR_FoEx_Report_Repression_of_Expression_The_State_of_Free_Speech%20in_Cambodia_EN.pdf.

[3] See for instance, *The World Law Guide: Legislation Cambodia.* Accessed 14 September 2015. www.lexadin.nl/wlg/legis/nofr/oeur/lxwecam.htm

[4] Cambodian Center for Independent Media, *Challenges for Independent Media* (CCIM, 2014), p3, http://www.ccimcambodia.org/images/Challenges_for_Independent_Media_2014.pdf.

[5] Jϋrgen Habermas in Denis McQuail.2011. *McQuail's Mass Communication Theory (6th edition)* pp180.

អ្នករាយការណ៍គ្មានព្រំដែន គឺថា បើក្រលេកមើលទៅលើសិទ្ធិសេរីភាពរបស់ប្រព័ន្ធផ្សព្វផ្សាយវិញ ទោះជាកម្ពុជាមាន «សេរីភាព» ច្រើនជាងប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើន (លើកលែងប្រទេសថៃ) ក៏ដោយ ក៏កម្រិតនេះនៅទាបជាងមធ្យមនៅឡើយ ពោលគឺថិតក្នុងលេខរៀងទី១៣៩ ក្នុងចំនោម១៧៨ ប្រទេស។[6] សន្ទស្សន៍ពិន្ទុរបស់ប្រទេសទាំងនេះបានមកពីទស្សនៈជាច្រើនដែលមានទៅលើប្រព័ន្ធផ្សព្វផ្សាយខ្លួនទាក់ទងទៅនឹង៖

- ភាពឯករាជ្យនៃប្រព័ន្ធផ្សព្វផ្សាយ
- បរិយាកាសនៃការប្រកបការងាររបស់អ្នកសារព័ត៌មាន និងការធ្វើការហាមឃាត់ដោយខ្លួនឯងនូវការបញ្ចេញមតិ និងទស្សនៈ
- ក្របខ័ណ្ឌច្បាប់
- តម្លាភាព
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រការផលិតព័ត៌មាន និង
- ការរំលោភបំពានដែលអ្នកសារព័ត៌មានទទួលរង។

មានសារៈប្រយោជន៍ប្រសិនជាសមាជិកព្រឹទ្ធសភាបានយល់ច្បាស់អំពី៖

- សក្តានុពលរបស់ប្រព័ន្ធផ្សព្វផ្សាយ
- ដំណើរការរបស់ប្រព័ន្ធផ្សព្វផ្សាយ និង
- មធ្យោបាយដែលសមាជិកព្រឹទ្ធសភាអាចប្រើប្រាស់ដើម្បីធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយដើម្បីពង្រឹងសិទ្ធិសេរីភាពសារព័ត៌មាន និងលើកកម្ពស់មុខមាត់ប្រទេសកម្ពុជានៅលើឆាកអន្តរជាតិលើផ្នែកសារព័ត៌មាន។

ចំនុចទីពីរដែលបច្ចុប្បន្នកម្ពុជានៅមិនទាន់មានភាពរឹងមាំនៅឡើយ គឺជាតម្រូវការរបស់អ្នកសារព័ត៌មានឲ្យមានការបណ្តុះបណ្តាលយ៉ាងពេញលេញដើម្បីយល់ពីសារសំខាន់នៃតួនាទីរបស់ពួកគាត់ និងអាចបំពេញការងារទាំងនោះក្នុងលក្ខណៈដែលមានសីលធម៌។ ប្រទេសកម្ពុជាបានអនុវត្តល្អនៅត្រង់ចំណុចនេះ។ ឧទាហរណ៍ នាពេលបច្ចុប្បន្ន សាកលវិទ្យាល័យនានា ដូចជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ផ្តល់ជូននូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈស៊ីជម្រៅសម្រាប់អ្នកសារព័ត៌មានដែលរួមបញ្ចូលការអនុវត្តន៍ប្រកបដោយវិជ្ជាជីវៈ ជាផ្នែកដ៏ចប្បងមួយនៃវគ្គបណ្តុះបណ្តាល។ លើសពីនេះទៀត អង្គការនានា ដូចជា មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងក្លឹបអ្នកសារព័ត៌មានកម្ពុជា បាននឹងកំពុងផ្តល់ការគាំទ្រដល់អ្នកសារព័ត៌មានឯករាជ្យ ព្រមទាំងផ្តល់ជូននូវក្រមសីលធម៌ វិជ្ជាជីវៈនានា ដើម្បីបង្កើតឲ្យមានសុច្ចរិតភាព និងវិជ្ជាជីវៈនៅក្នុងការងារ ប្រចាំថ្ងៃរបស់

[6] *Reporters Without Borders 2015 World Press Freedom Index*. Accessed 14 September 2015: https://index.rsf.org

គាត់។[7] ទោះបីជាយ៉ាងណាក៏ដោយ អង្គការទាំងនេះទទួលស្គាល់ថា វគ្គបណ្តុះបណ្តាលសមស្របមួយ ត្រូវផ្តល់ជូនអ្នកសារព័ត៌មានបន្ថែមទៀត ដោយភ្ជាប់ជាមួយការទទួលខុសត្រូវពាក់ព័ន្ធនានា ដើម្បីឲ្យពួកគាត់យល់ដឹងអំពីតួនាទីរបស់ខ្លួននៅក្នុងការភ្ជាប់ទំនាក់ទំនងសមាជិកសភាជាមួយប្រជាជន និងភ្ជាប់ទំនាក់ទំនងពីប្រជាពលរដ្ឋត្រលប់មកសមាជិកសភាវិញ។ ស្របពេលជាមួយគ្នានេះដែរ អ្នកសរសេររបាយការណ៍ចាំបាច់ត្រូវយល់ដឹងបន្ថែមទៀត អំពីរបៀបដែលសមាជិកសភាកម្ពុជាអនុវត្តការងារ និងបំពេញមុខងាររបស់ពួកគាត់។ ការណ៍ដែលធ្វើដូចនេះនឹងធ្វើឲ្យមានការយោគយល់អាធ្យាស្រ័យគ្នាកាន់តែប្រសើរ។ ទន្ទឹមនឹងនេះដែរ វគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងប្រធានបទនេះនឹងអាចជាប្រយោជន៍សម្រាប់អ្នកសរសេររបាយការណ៍ផងដែរ។

បន្ថែមលើនេះទៀត យន្តការនានាដែលអនុញ្ញាតឲ្យអ្នកសរសេររបាយការណ៍អាចជួបជាមួយសមាជិកសភា និងអាចទទួលបាននូវព័ត៌មានពាក់ព័ន្ធនឹងបញ្ហារបស់រាជរដ្ឋាភិបាល ក៏មានសារសំខាន់ព្រមគ្នាផងដែរ ហើយសមាជិកសភាទំនងជាអាចពិចារណាទៅលើយន្តការទាំងនេះ។[8] បើទោះបីជានៅក្នុងប្រទេសដែលជាសមាជិកអាស៊ានផ្សេងទៀត ការទទួលបាននូវព័ត៌មានទាំងនេះហាក់បីដូចជាត្រូវបានត្រួតពិនិត្យយ៉ាងតឹងរឹងក៏ដោយ ក៏ប្រព័ន្ធផ្សព្វផ្សាយត្រូវបានគេមើលឃើញថាមិនមែនជាឧបករណ៍របស់អ្នកផ្តល់ព័ត៌មានឯករាជ្យទេ តែជាឧបករណ៍របស់រដ្ឋាភិបាលច្រើនជាង។[9] ប្រទេសលោកខាងលិចមួយចំនួនបានបង្កើតយន្តការនានា ដែលរៀបចំឡើងដើម្បីសម្របសម្រួលការទំនាក់ទំនងប្រកប ដោយផលិតភាព និងពោរពេញទៅដោយសេរីភាពរវាងអ្នកសារព័ត៌មាន និងសមាជិកសភា។ ឧទាហរណ៍ អ្នកសារព័ត៌មាន និងអ្នកសរសេររបាយការណ៍ របស់សហរដ្ឋអាមេរិកនៅសេតវិមាន ចាំបាច់ត្រូវទទួលស្គាល់ជាផ្លូវការពីគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការឆ្លើយឆ្លង ដែលត្រូវបានបោះឆ្នោតដោយអ្នកសារព័ត៌មាន និងអ្នកសរសេររបាយការណ៍ ដែលទទួលស្គាល់ជាផ្លូវការ។ ពួកគាត់ត្រូវធ្វើការស្ថាប័នសារព័ត៌មានមួយ ព្រមទាំងត្រូវតែឯករាជ្យ ដែលជាលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដទៃផ្សេងទៀត។ សេតវិមានក៏តម្រូវឲ្យមានអង្គភាពសើបអង្កេតសម្ងាត់ ការត្រួតពិនិត្យផងដែរ។ អ្នកសរសេររបាយការណ៍ដែលត្រូវគេទទួលស្គាល់ថាមានជោគជ័យ ត្រូវបាន

[7] See the Code of Ethics for Cambodian Journalists on the CCIM website: www.ccimcambodia.org/code-of-ethics
[8] For instance, in their publication *Challenges for Independent Media 2014,* the Cambodian Center for Independent Media (p9) cite the comments of reporters lamenting difficulties in access to information about government actions and policies, and a lack of "officials' competencies" in responding to journalists' requests for information. In their *Country Case Study: Cambodia: Support to media where media freedoms and rights are constrained (*p6), BBC Media Action in August 2012, makes similar points.
[9] See, for instance, Zaharom Nain: Globalized theories and national controls: The state, the market, and the Malaysian media, in James Curran and Myung-Jin Park (eds.). 2000. *De-Westernizing Media Studies.* New York: Routledge, and the UNESCO-funded publication from Article 19 (the organization named after the relevant article in the Universal Declaration of Human Rights), called *Freedom of Expression and the Media in Thailand.*2005. Accessed 14 September 2015. https://www.article19.org/data/files/pdfs/publications/thailand-baseline-study/pdf

អនុញ្ញាតឲ្យចូលរួមកិច្ចប្រជុំរយៈពេលខ្លីជាទៀងទាត់ ក៏ដូចជាចូលជួបជាមួយអ្នកនយោបាយផងដែរ។[10] ជាឧទាហរណ៍នៃយន្តការមួយផ្សេងទៀត គឺការចូលជួបរបស់អ្នកសារព័ត៌មានអង់គ្លេសជាមួយសមាជិកសភាដែលបានបង្កើតឡើងជាច្រើនសតវត្សរ៍មកហើយ៖

- ចំនួនអ្នកសារព័ត៌មាន និងអ្នកសរសេររបាយការណ៍នៅរដ្ឋសភាមានការកើនឡើងជាបន្តបន្ទាប់ បើទោះបីជាមានការរិះគន់ជាញឹកញាប់អំពីទំនាក់ទំនងយ៉ាងជិតស្និទពេករវាងអ្នកសារព័ត៌មាន និងសមាជិកសភាក៏ដោយ[11]
- «មធ្យោបាយបន្ទប់រងចាំ» (Lobby System) អនុញ្ញាតឲ្យក្រុមសារព័ត៌មាន និងអ្នកសរសេររបាយការណ៍ដែលបានជ្រើសរើសដើម្បីចូលទៅក្នុងទីកន្លែងមួយដែលពួកគាត់អាចធ្វើបទសម្ភាសន៍ជាមួយសមាជិកសភាដោយផ្ទាល់។[12] ឈ្មោះ Lobby System នេះចេញមកពីការពិតដែលថាអ្នកសារព័ត៌មានមានសិទ្ធិចូលទៅក្នុង «បន្ទប់រង់ចាំរបស់សមាជិកសភា (Member′s Lobby )» របស់សភានៃចក្រភពអង់គ្លេស។ ព័ត៌មានដែលអ្នកសារព័ត៌មានប្រមូលបាននៅទីនេះ មិនអាចបញ្ជាក់ពីឈ្មោះប្រភពបានឡើយ ប៉ុន្តែអាចធ្វើការរាយការណ៍បាន។ អ្នកសារព័ត៌មាននៅបន្ទប់រង់ចាំ ក៏ត្រូវអញ្ជើញឲ្យចូលទៅក្នុងការិយាល័យរបស់នាយករដ្ឋមន្ត្រី (ផ្ទះលេខ១០ ផ្លូវ Downing) ផងដែរ សម្រាប់កិច្ចប្រជុំជាទៀងទាត់រយៈពេលខ្លី «ដោយមិនមានការកត់ត្រា (off the record)» ដែលពួកគាត់ប្រហែលជាមិនអាចកត់ត្រា ប៉ុន្តែ អាចផ្តល់ជាមូលដ្ឋានព័ត៌មានដ៏មានសារសំខាន់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍គោលនយោបាយបច្ចុប្បន្ន។

ទោះបីជា យន្តការនានានៅប្រទេសលោកខាងលិចទាំងនេះ ប្រហែលជាមិនអាចអនុវត្តនៅប្រទេសកម្ពុជាទាំងស្រុងក៏ដោយ ក៏ដំណើរការមួយដែលមានលក្ខណៈជាប្រព័ន្ធដែលអនុញ្ញាតឲ្យមានលំហូរព័ត៌មានពីសមាជិកសភាទៅកាន់សារព័ត៌មាន និងពីសារព័ត៌មានទៅកាន់សមាជិកសភាគប្បីយកមកពិចារណា។

---

[10] Joshua Keating. June 7 2010. *Can the White House Revoke a Reporter's Credentials?* Foreign Policy. Accessed 14 September 2015. foreignpolicy.com/2010/06/07/can-the-white-house-revoke-a-reporters-credentials/

[11] David Aaronovitch. 7 May 2002. *The media column: The lobby system poisons political journalism.* Accessed 14 September 2015: www.independent.co.uk/news/media/the-media-column-the-lobby-system-poisons-political-journalism-650494.html

[12] For example, *Lobby Journalism*, on the UK Parliament website. Accessed 14 September 2015. http://www.parliament.uk/about/living-heritage/evolutionofparliament/parliamentwork/communicating/overview/lobbyjournalism/. And *Lobby Correspondents.* On the BBC website. Accessed 14 September 2015. http://news.bbc.co.uk/2/hi/uk_news/politics/h-l/82525.stm

## ២. តម្រូវការដែលបានលើកឡើងសម្រាប់ការពង្រឹងសមត្ថភាព

ដើម្បីបន្តមុខងារតំណាងរបស់ខ្លួន សមាជិកសភាត្រូវតែមានទំនាក់ទំនងទៅវិញទៅមកជាមួយប្រជាពលរដ្ឋ៖ សមាជិកសភាត្រូវប្រាប់ទៅប្រជាជននូវព័ត៌មានអំពីច្បាប់ និងគោលនយោបាយការអនុវត្តន៍ការតាក់តែងច្បាប់ ហើយស្របពេលនោះដែរគឺត្រូវស្តាប់នូវក្តីបារម្ភ និងសំណូមពររបស់ប្រជាជន ដើម្បីផ្តល់ព័ត៌មានអំពីដំណើរការតាក់-តែងច្បាប់នៅថ្ងៃអនាគត។ ជាការពិតណាស់ ឯកសារយុទ្ធសាស្ត្រដែលផលិតដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា[13] បញ្ជាក់ពីតម្រូវការនេះក្នុងករណីមួយចំនួន។ ឧទាហរណ៍ ឯកសារទាំងនោះបានបង្ហាញពីតម្រូវការដូចជា៖

- ពង្រឹងសមត្ថភាពសមាជិកព្រឹទ្ធសភាដើម្បីរៀបចំសកម្មភាពចុះមូលដ្ឋាន ជាពិសេសផ្សព្វផ្សាយព័ត៌មានថ្មីៗទៅឲ្យប្រជាពលរដ្ឋ ដើម្បីឲ្យពួកគាត់ដឹងពីតួនាទី ការទទួលខុសត្រូវ និងសកម្មភាពរបស់ព្រឹទ្ធសភា
- បង្កើតជំនាញទំនាក់ទំនងសាធារណៈដើម្បីកែប្រែទស្សនៈរបស់សាធារណៈជន និងរបៀបរបបធ្វើការស្ថាប័នព្រឹទ្ធសភា
- លើកកម្ពស់ការយល់ដឹងរបស់សាធារណៈជនទៅលើដំណើរការ និងតួនាទីរបស់សភាត្រូវបានទទួលតាមរយៈការចូលរួមជាមួយប្រជាជន និង
- ឲ្យដឹងថា ប្រជាជនកម្ពុជាខ្លួនឯងគឺជាអ្នកដែលអនុវត្តលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ឆន្ទៈ របស់ប្រជាពលរដ្ឋនេះហើយដែលកកើតឡើងតាមរយៈទំនាក់ទំនងសាធារណៈដែលត្រឹមត្រូវ អាចធ្វើឲ្យការចុះបេសកកម្មរបស់សមាជិកសភាមានប្រសិទ្ធភាព។

ឯកសារយុទ្ធសាស្ត្រព្រឹទ្ធសភាទាំងនេះក៏មានភាពស្របគ្នាទៅនឹងបទពិសោធន៍ពីប្រទេសនានាដែរ[14] ដែលគាំទ្រទៅលើទស្សនៈថា ប្រសិនប្រជាពលរដ្ឋត្រូវមានការគោរព និងទុកចិត្តសភារបស់ខ្លួន ពួកគេត្រូវដឹងអំពីការងារ និងតួនាទីរបស់សភា និងត្រូវតែប្រាកដថាការចូលរួម និងការគោរពសភាគឺជារឿងល្អ និងគួរឲ្យចាប់អារម្មណ៍។

[13] General Secretariat of the Senate. 2014. *Study on the Strategic Framework and Activity Plan for 10 Years of Capacity Strengthening for the Cambodian Senate (2014-2024)* and General Secretariat of the Senate. 2014. *The Study on the Ten-Year Perspective of the General Secretariat of the Senate (2014-2024).*

[14] The Hansard Society. 2010. *Lessons from Abroad: How Parliaments Around the World Engage with their Public*, a report from the Group on Information for the Public, UK Parliament.

## ៣. ការពង្រឹងជំនាញទំនាក់ទំនងសម្រាប់សមាជិកសភាក្នុងការគាំទ្រនូវមុខងារជាតំណាង

### ៣.១ យុទ្ធសាស្ត្រនៃទំនាក់ទំនង និងផែនការផ្សារភ្ជាប់

ការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ គឺជាផ្នែកមួយដ៏សំខាន់នៃមុខងារជាតំណាងរបស់តំណាងរាស្ត្រ។ ការបង្កើតនូវជំនាញ និងចំណេះដឹងក្នុងការផ្សារភ្ជាប់នេះ អាចជួយគាំទ្រដល់តំណាងរាស្ត្រក្នុងការបំពេញតួនាទីរបស់ខ្លួន។ សំខាន់បំផុតនោះគឺមគ្គុទេសក៍នៃការអនុវត្តន៍ល្អៗបានបង្ហាញថា យុទ្ធសាស្ត្រនៃទំនាក់ទំនង និងផែនការនៃការផ្សារភ្ជាប់អាចជួយធ្វើឲ្យមានប្រយោជន៍ជាអតិបរមា។[15] ជាការចាប់ផ្តើម យុទ្ធសាស្ត្រអាចជួយឲ្យគោលបំណងនៃសកម្មភាពទំនាក់ទំនងមានភាពប្រសើរ។[16] ទាំងនេះនឹងក្លាយជាកញ្ចក់ឆ្លុះបញ្ចាំងនូវគោលបំណងទាំងនោះដែលមានរំលេចឡើងនៅក្នុងឯកសារយុទ្ធសាស្ត្ររបស់ព្រឹទ្ធសភា (មានការរៀបរាប់ខាងលើ) និងមានលក្ខណៈជាអន្តរ-ជាតិនៅក្នុងការអនុវត្តន៍។ ប៉ុន្តែការផ្តល់សារដោយតំណាងរាស្ត្រទៅកាន់ក្រុមប្រជាពលរដ្ឋរបស់ពួកគេនឹងមានភាពខុសគ្នា។ ឧទាហរណ៍ ការផ្តល់សារដល់ប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទដាច់ស្រយាល នឹងគ្របដណ្តប់ទៅលើប្រធានបទ ដែលខុសពីសារទៅកាន់ក្រុមសហគមន៍ធុរៈកិច្ច សហការីនៅសភា ឬក្រុមជំនាញនៅតំបន់ទីប្រជុំជនដែលទទួលបានការអប់រំខ្ពស់។ ភាសានៃការប្រើប្រាស់នឹងមានភាពខុសគ្នាក្នុងគោលបំណង ដើម្បីផ្សារភ្ជាប់ទៅនឹងតម្រូវការរបស់ក្រុមគោលដៅផ្សេងៗគ្នា។ ការណែនាំក្នុងការកំណត់ភាពផ្សេងគ្នាទៅលើក្រុមគោលដៅ និងវិធីសាស្ត្រលទ្ធផលក្នុងការខិតជិតក្រុមគោលដៅនីមួយៗមាននៅក្នុងឯកសារ ដូចជា មគ្គុទេសក៍ធនធាននៃក្រុមប្រឹក្សាអន្តរជាតិសម្រាប់ការផ្តួចផ្តើមផ្នែកបរិស្ថានមូលដ្ឋាន៖ ដែលរៀបរាប់អំពីការចុះមូលដ្ឋាន និងទំនាក់ទំនង ដែលផ្តោតលើរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវផ្សារភ្ជាប់សមាជិកសហគមន៍ក្នុងសកម្មភាពរបស់ពួកគេពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។[17]

ភ្ជាប់នឹងការរៀបរាប់ខាងលើនេះ ការកំណត់នូវមធ្យោបាយដែលស័ក្តិសមបំផុតក្នុងការទំនាក់ទំនងគឺជារឿងសំខាន់។ នៅតាមតំបន់ដែលតំណាងរាស្ត្រចុះមូលដ្ឋានអាចទៅដល់ និងមានលក្ខណៈងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុង

---

[15] The UK Government's *Government Communications Plan 2015/16* is an example of a plan that identifies aims and reviews past practice. It can be accessed at: https://communication.cabinetoffice.gov.uk/government-comms-plan/wp-content/uploads/2015/07/GCS-Government-Communications-Plan-1516.pdf

[16] See, for instance, *Writing a Communication Strategy,* published by the UK Government Communication Service in 2014. Accessible at: https://gcn.civilservice.gov.uk/wp-content/uploads/2014/04/Writing-a-communication-strategy-GCS-Guide.pdf

[17] ICLEI Resource Guide 2009. Outreach and Communications. Accessed at: www.usclimatenetwork.org/resource-database/Outreach and Communications Guide.pdf

ការប្រមូលផ្តុំ ដែលអាចពួកគាត់ជួបជាមួយប្រជាពលរដ្ឋផ្ទាល់គឺមានសារៈសំខាន់ណាស់។ តែទោះបីជាយ៉ាងណាក៏ដោយក្នុងការផ្សារភ្ជាប់ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដាច់ស្រយាល តំណាងរាស្ត្រប្រហែលជាត្រូវពឹងផ្អែកទៅលើវិទ្យុ។ ទូរទស្សន៍ និងកាសែត ជាមធ្យោបាយផ្សេងទៀតដើម្បីផ្សារភ្ជាប់ប្រជាពលរដ្ឋជាច្រើនទៀតក្នុងពេលជាមួយគ្នា។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននឹងមានរៀបរាប់ជូនក្នុងផ្នែកបន្ទាប់។

## ៣.២ បណ្តាញសង្គម

ពាសពេញពិភពលោក ជាពិសេសប្រទេសក្រីក្រ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាគឺពិតជានៅមានកម្រិត ដូច្នេះប្រព័ន្ធផ្សព្វផ្សាយព័ត៌មានតាមបែបបុរាណនៅតែមានសារៈសំខាន់។ ប៉ុន្តែក្នុងការខិតជិតក្រុមគោលដៅដែលជាយុវជនវ័យក្មេងក្នុងពេលបច្ចុប្បន្ននេះ ការប្រើប្រាស់បណ្តាញសង្គម ជាពិសេសតាមរយៈ Facebook និងYoutube កាន់តែមានប្រសិទ្ធភាពសម្រាប់សមាជិកសភានៅលោកខាងលិច ដែលមានបំណងបង្កើននូវការគាំទ្រក្នុងចំណោមអ្នកបោះឆ្នោតដែលជាយុវជនវ័យក្មេង ហើយនិន្នាការនេះកំពុងកើនឡើងនៅក្នុងប្រទេសនានាផងដែរ រួមទាំងកម្ពុជា។[18] នៅក្នុងឆ្នាំ២០១២ អ្នកប្រើប្រាស់ Facebook មានប្រមាណ៧៥០ លាននាក់ ទូទាំងពិភពលោក ហើយក្នុងមួយនាទី វីដេអូដែលត្រូវបានដាក់បញ្ចូលទៅក្នុងYoutube មានប្រមាណ ៦០ ម៉ោង ។[19] តួលេខទាំងនោះត្រូវបានសន្មតថានៅតែបន្តកើនឡើង។ នៅក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសប្រធានាធិបតីនៃសហរដ្ឋ-អាមេរិក ឆ្នាំ២០០៨ វីដេអូតាមអ៊ិនធឺណែតស្តីពីការបោះឆ្នោតនេះត្រូវបានចូលមើលច្រើនជាងចំនួនមួយកោដិដង[20] រីឯសភារបស់ចក្រភពអង់គ្លេសមានគេហទំព័រ Youtube របស់ខ្លួនផ្ទាល់។ ជាងនេះទៅទៀត ការអង្កេតដែលធ្វើឡើងដោយ Hansard Society នៅក្នុងឆ្នាំ២០០៩ បានឲ្យដឹងថាសមាជិកសភានៃចក្រភពអង់គ្លេសមានការកើនឡើងក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយឌីជីថល ក្នុងការទំនាក់ទំនងជាមួយម្ចាស់ឆ្នោត។[21]

នៅក្នុងប្រទេសកម្ពុជា ឥស្សរជនដឹកនាំសំខាន់ៗជាច្រើនរួមមានតំណាងរាស្ត្រ និងរដ្ឋមន្ត្រី នាពេលបច្ចុប្បន្នបានបង្ហោះព័ត៌មាន និងទំនាក់ទំនងផ្សេងៗ នៅក្នុង Facebook ហើយនៅក្នុងឆ្នាំ២០១៥ ក្រុមទំនាក់ទំនងនៃក្រសួងកិច្ចការនារីបានទទួលវគ្គបណ្តុះបណ្តាលពី Deutsche Welle Akademie ក្នុងការប្រើប្រាស់ Facebook ដើម្បី

[18] Centre for European Studies ( undated). *Social Media – the New Power of Political Influence.*
[19] Katy Howell. 2012. An Introduction to Social Media. in *Share This: The Social Media Handbook for Professionals.*pp4.
[20] Nikki Schwab. 2008. In Obama-McCain Race, YouTube Became a Serious Battleground for Presidential Politics. http://www.usnews.com/news/campaign-2008/articles/2008/11/07/in-obama-mccain-race-youtube-became-a-serious-battleground-for-presidential-politics
[21] Andy Williamson. 2009. *MPs Online: Connecting with Constituents*. Hansard Society

ផ្សព្វផ្សាយបញ្ហារបស់ស្ត្រី។[22] ដូច្នេះ Facebook អាចផ្តល់នូវមធ្យោបាយក្នុងការបញ្ជូននូវសារសំខាន់ៗ ឬក៏ផ្សព្វផ្សាយពីឥស្សរជនសំខាន់នៅក្នុងផ្លូវវិជ្ជមាន។

ទោះបីយ៉ាងណាក៏ដោយ ប្រព័ន្ធបណ្តាញសង្គមអាចផ្តល់នូវបញ្ហា រួមទាំងផលប្រយោជន៍។ កាលពីពេលមុនៗដែលមិនធ្លាប់មាន ការបញ្ចេញមតិបែបអវិជ្ជមានបង្ហោះនៅលើ Facebook អំពីបុគ្គលម្នាក់ ផលិតផល ក្រុមហ៊ុន ឬក៏គណបក្សនយោបាយមួយ អាចត្រូវបានចែករំលែកទៅកាន់អ្នកផ្សេងទៀត ដែលធ្វើឲ្យមានការខាតបង់នូវកិត្យានុភាព ឬផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង។ ឧទាហរណ៍ដែលមានលក្ខណៈជាអន្តរជាតិថ្មីៗនេះ គឺវាសនានៃលោក Walter Palmer ដែលជាទន្តពេទ្យសញ្ជាតិអាមេរិកដែលបានប្រមាញ់ និងសម្លាប់ Cecil ដែលជាសត្វតោ ដែលគួរឲ្យស្រលាញ់បំផុត និងទាក់ទាញនៅក្នុងសួនឧទ្យានជាតិនៃឧទ្យានជាតិរបស់ប្រទេស Zimbabwe។ តោនោះត្រូវបានគេគាំទ្រដោយមហាជនតាមរយៈប្រព័ន្ធអ៊ិនធឺណែត និងសាកលវិទ្យាល័យ Oxford ក៏បានធ្វើការសិក្សាស្រាវជ្រាវផងដែរ។ ការធ្វើឲ្យសត្វតោនោះឈឺចាប់បន្តិចម្តងៗយ៉ាងវេទនារហូតដល់ស្លាប់បាត់បង់ជីវិត ហើយប្រហែលជាខុសច្បាប់ទៀតផងដែរ បានបង្កនូវកំហឹងដល់មហាជនទូទាំងពិភពលោក និងបានបង្ខំឲ្យលោក Walter Palmer ត្រូវបង្ខំចិត្តធ្វើការគេចខ្លួន។[23] ដូច្នេះអត្ថិភាពនៃបណ្តាញសង្គមមានន័យថា សកម្មភាពអវិជ្ជមានអាចផ្តល់នូវផលប៉ះពាល់ផ្សេងៗ និងអាចត្រូវបានផ្សព្វផ្សាយទៅប្រជាពលរដ្ឋរាប់លាននាក់នៅទូទាំងពិភពលោកដឹងថាឧក្រិដ្ឋជនគឺជាអ្នកណា។ ដូច្នេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋទាំងអស់គ្នាក្នុងសង្គមដែលយល់ដឹងពីគ្រោះថ្នាក់រួមទាំងផលប្រយោជន៍ ដែលមធ្យោបាយទំនាក់ទំនងថ្មីៗទាំងនេះផ្តល់ឲ្យ។ នេះក៏មានសារៈ-សំខាន់ផងដែរ ក្នុងការយកចិត្តទុកដាក់អំពីប្រភេទនៃបណ្តាញសង្គម «ដែលមិនអាចគ្រប់គ្រងបាន» នៅពេលដែលអត្ថបទ ឬវីដេអូដែលត្រូវបានផ្សព្វផ្សាយតាមអ៊ិនធឺណែតហើយ វាពិតជាមានការលំបាកក្នុងការទប់ស្កាត់នូវការចែករំលែកនូវអត្ថបទ ឬវីដេអូទាំងនោះ និងក្នុងពេលដែលអ៊ិនធឺណែតក្នុងបរិបទអន្តរជាតិមានការលំបាកក្នុងការចាត់វិធានការច្បាប់។

---

[22] Jeanette Seiffert. 3 July 2015. *Cambodia: Using Facebook for women's rights.* Accessed at: www.dw.com/en/cambodia-using-facebook-for-womens-rights/a-18558528

[23] Among many newspapers around the world to give extensive coverage to Walter Palmer and the killing of Cecil the lion, *The Telegraph* (a leading UK newspaper) gave a detailed account on 26 August 2015, along with first images of the elusive dentist since he went into hiding. This can be accessed at: http://www.telegraph.co.uk/news/worldnews/northamerica/usa/11806856/walter-palmer-cecil-the-lion-killer-first-pictures.html

ទោះបីជា Twitter មិនត្រូវបានប្រើប្រាស់ទូលំទូលាយទេ បទពិសោធន៍នៃប្រទេសផ្សេងៗទៀត បានបង្ហាញថា Twitter នេះ ប្រហែលជានឹងអាចមានការពេញនិយមនាពេលអនាគត។[24] នៅក្នុងឆ្នាំ២០១៣ សហព័ន្ធអន្តរសភា បានបោះពុម្ព *គោលការណ៍ណែនាំអំពីបណ្តាញសង្គមសម្រាប់សភា* ដែលផ្តល់នូវទស្សនទានទូទៅនៃមធ្យោបាយនានាដែលបណ្តាញសង្គមអាចត្រូវបានប្រើប្រាស់សម្រាប់កិច្ចការសភា រួមទាំងការប្រតិបត្តិតាម និងបញ្ហាច្បាប់នានា យុទ្ធសាស្ត្រ និងឧទាហរណ៍នៃការអនុវត្តន៍បាននានា។[25]

## ៣.៣ យុទ្ធនាការផ្សព្វផ្សាយសង្គម (ព័ត៌មានសាធារណៈ)

យុទ្ធនាការផ្សព្វផ្សាយសង្គមមានតួនាទីសំខាន់នៅក្នុងការជំរុញស្ថាប័នរដ្ឋាភិបាល អ្នកនយោបាយ និងអ្នកផ្សេងៗទៀតនៅក្នុងមុខតំណែងខ្ពស់ៗ ក្នុងការដោះស្រាយបញ្ហាកង្វល់ផ្ទាល់ជាមួយប្រជាពលរដ្ឋ។ បញ្ហាទាំងនេះមិនជារឿងនយោបាយ ឬក៏ជាវិវាទអ្វីទេ តែក្នុងគោលបំណងផ្តល់ព័ត៌មានដែលជួយដល់ប្រជាពលរដ្ឋក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។ ការដឹងអំពីប្រភេទជំងឺធ្ងន់ធ្ងរមុនពេលគ្រោះថ្នាក់ដល់ជីវិត ការកែលម្អអំពីការញ៉ាំអាហារ និងការហាត់ប្រាណ ការប្រាប់ឲ្យដឹងជាមុននូវគ្រោះថ្នាក់នៃទឹកមិនស្អាត និងការបោះសំរាមដោយមិនមានអនាម័យ សុទ្ធតែជាប្រធានបទក្នុងចំណោមប្រធានបទជាច្រើនទៀតដែលអាចកើតមាន ដែលរដ្ឋាភិបាល និងតំណាងរបស់ប្រជាពលរដ្ឋត្រូវផ្តល់ព័ត៌មានជាសាធារណៈ។[26] ទោះបីជា មានការលើកឡើងថាមានការពាក់ព័ន្ធតិចតួចរបស់តំណាងរាស្ត្រលើកកិច្ចការនេះជាងបុគ្គលិកនៅសភា ឬមន្ត្រីរបស់ក្រសួងរបស់រដ្ឋាភិបាលក៏ដោយ ក៏យុទ្ធនាការផ្សព្វផ្សាយសង្គមគឺជាឧបករណ៍ដ៏សំខាន់ ក្នុងការផ្សារភ្ជាប់តំណាងរាស្ត្រជាមួយនឹងម្ចាស់ឆ្នោតតាមមធ្យោបាយដែលផ្តោតទៅលើកង្វល់របស់តំណាងរាស្ត្រសម្រាប់សុខមាលភាពរបស់ប្រជាពលរដ្ឋ។ យុទ្ធនាការនេះគឺប្រើប្រាស់នូវគោលការណ៍ និងការអនុវត្តន៍នានានៃការផ្សព្វផ្សាយទីផ្សារ ដើម្បីផ្សព្វផ្សាយព័ត៌មានជាសាធារណៈ[27] និងប្រើប្រាស់វិធីសាស្ត្រនៃការផ្សព្វផ្សាយពាណិជ្ជកម្មក្នុងការបញ្ចុះបញ្ចូលប្រជាពលរដ្ឋ ដើម្បីផ្លាស់ប្តូរទំលាប់ និងអាកប្បកិរិយា។ ជាញឹកញាប់ការងារនេះបានគាំទ្រពីសំណាក់ស្ថាប័នពាក់ព័ន្ធផ្សេងៗ ជាពិសេសស្ថាប័នផ្នែកសុខភាព ឬភ្នាក់ងារបរិស្ថាន ដើម្បី

---

[24] Alex Lacey. 2012. Twitter: The Unstoppable Rise of Microblogging. In: *Share This: The Social Media Handbook for Professionals.* P71

[25] Andy Williamson. 2013. *Social Media Guidelines for Parliaments*. Inter-Parliamentary Union. Accessible at: www.ipu.org/PDF/publications/SMG2013EN.pdf

[26] Gerard Hastings and Laura McDermott. 2006. Putting social marketing into practice. BMJ May 20; 332(7551): 1210-1212

[27] Adam Corner and Alex Randall. 2011. Selling climate change? The limitations of social marketing as a strategy for climate change public engagement. *Global Environment Change*. 21. 1005-1014. And Tony Proctor. 2007. *Public Sector Marketing.* London: Prentice Hall

ធានាថាយុទ្ធនាការទាំងនេះគ្របដណ្តប់ឲ្យបានទូលំទូលាយបំផុត នៅតាមតំបន់ដែលប្រជាពលរដ្ឋច្រើនតែមានការចាប់អារម្មណ៍។[28]

## ៣.៤ ជំនាញក្នុងការនិយាយ

ប្រសិទ្ធភាពនៃយុទ្ធសាស្ត្រទំនាក់ទំនង និងប្រសិទ្ធផលនៃភាពខុសគ្នាក្នុងមធ្យោបាយទំនាក់ទំនងទទួលផលប្រយោជន៍ពីការអភិវឌ្ឍជំនាញក្នុងការនិយាយ[29] ឧទាហរណ៍ ការរៀបចំ និងការធ្វើសុន្ទរកថាអាចមានប្រយោជន៍ពីការអនុវត្តគោលការណ៍មូលដ្ឋានមួយចំនួន។[30] តើអ្វីដែលជាខ្លឹមសារសំខាន់ៗរបស់សុន្ទរកថា? តើនរណាជាក្រុមគោលដៅ? តើសុន្ទរកថាទាំងនោះពាក់ព័ន្ធនឹងពួកគេលើបញ្ហាអ្វីខ្លះ? តើវិធីសាស្ត្រអ្វីខ្លះដែលដំបូងធ្វើឲ្យអ្នកអានសុន្ទរកថាទាក់ទាញការយកចិត្តទុក ហើយរក្សាការយកចិត្តទុកដាក់របស់អ្នកស្តាប់រហូតដល់ចប់សុន្ទរកថា?

អ្នកជំនាញមុនៗបានកំណត់ពីភាសាវិទ្យា និងវិធីសាស្ត្រផ្សេងៗទៀត។ សុន្ទរកថាស្តីពី *ខ្ញុំមានសុបិន្តមួយ របស់* Dr. Martin Luther King *ដែលបានធ្វើឡើងក្នុងឆ្នាំ១៩៦៣ គឺជាគន្លឹះក្នុងការបង្កើតនូវកម្លាំងនយោបាយដែលជំរុញឲ្យមានច្បាប់ស្តីពីសិទ្ធិស៊ីវិលនៅឆ្នាំ១៩៦៤។* ចំណែកសុន្ទរកថារបស់លោក Winston Churchill «*យើងនឹងប្រយុទ្ធប្រឆាំងនៅលើឆ្នេរសមុទ្រ*» ដែលសុន្ទរកថានេះបានធ្វើឡើងទៅកាន់សភានៃចក្រភពអង់គ្លេសនៅក្នុងឆ្នាំ១៩៤០ ដែលបានក្លាយជាការជំរុញស្មារតីក្នុងការត្រៀមរៀបចំប្រយុទ្ធប្រឆាំងរបស់ចក្រភពអង់គ្លេសនៅពេលដែលខ្លួនឈានដល់ដំណាក់កាលដ៏លំបាកនៅសង្គ្រាមលោកលើកទី២។ ក្នុងខណៈដែលសុន្ទរកថារបស់លោក Abraham Lincoln ស្តីពី Gettysburg Address ដែលមានរយៈពេល ២នាទី បានថ្លែងនៅក្នុងឆ្នាំ ១៨៦៣ បច្ចុប្បន្ននៅតែមានការដកស្រង់ជាច្រើននៅពេលដែលគេគាំទ្រនូវតម្លៃនៃសេរីភាព និងប្រជាធិបតេយ្យ។ សុន្ទរកថាទាំង ៣នេះមានឥទ្ធិពលខ្លាំងក្លាទៅលើប្រជាពលរដ្ឋដែលបានស្តាប់នូវសុន្ទរកថាទាំងនោះ ហើយសុន្ទរកថានីមួយៗរួមមានវិធីសាស្ត្រក្នុងការផ្សារភ្ជាប់ក្រុមអ្នកស្តាប់ ឬក្រុមគោលដៅ ដែលអាចយកមកវិភាគ ឬប្រើប្រាស់នៅក្នុងការរៀបចំផ្សេងៗទៀត។[31]

---

[28] Many case studies can be found on the website of the UK-based National Social Marketing Centre: www.thensmc.com

[29] CIPR Skills Guide (undated). *Writing Great Speeches.* And Paul Richards 2004. *How to Win an Election.*pp97

[30] See, for instance, the EU-funded *Communications Handbook – Factsheet 12 Version 1: Presentations and Speeches.* April 2012. Produced by MED (Europe in the Mediterranean) Available at: http://www.programmemed.eu/fileadmin/PROG_MED/Communication_projets/Communication_GUIDANCE/Factsheet_12.pdf

[31] Jeff Schmitt. 2013 . 10 Keys to Writing a Speech. http://www.forbes.com/sites/jeffschmitt/2013/07/16/10-keys-to-writing-a-speech/

**PowerPoint** អាចដើរតួនាទីសំខាន់ក្នុងការគាំទ្រដល់ការធ្វើបទបង្ហាញ ប៉ុន្តែជាថ្មីម្តងទៀតវិធីសាស្ត្រនានាត្រូវការយកមកប្រើប្រាស់ និងវិធីសាស្ត្រមួយចំនួនដែលត្រូវជៀសវាង ដើម្បីឲ្យការបង្ហាញកាន់តែមានប្រសិទ្ធភាព។

## ៤. តើសមាជិកសភាអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីពង្រឹងតួនាទីភាពជាតំណាងយ៉ាងដូចម្តេច?

ដូចការពិភាក្សាខាងលើ សកម្មភាពចុះមូលដ្ឋានគឺជាផ្នែកមួយដ៏សំខាន់នៃមុខងារភាពជាតំណាងរបស់តំណាង-រាស្ត្រ។ ប៉ុន្តែទោះបីជាវាមានសារៈសំខាន់យ៉ាងណាក៏ដោយ ការចុះមូលដ្ឋានដើម្បីរៀបចំវេទិកា ការពិគ្រោះយោបល់ជាសាធារណៈ និងសកម្មភាពផ្សេងៗទៀត អាចធ្វើឲ្យតំណាងរាស្ត្រមានទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋបានចំនួនតិចតួចទេ៖ ហេតុដូច្នេះ ឱកាសសម្រាប់ទំនាក់ទំនង ឬឆ្លើយឆ្លង (Two-way communication) ជាមួយនឹងប្រជាពលរដ្ឋ ឬម្ចាស់ឆ្នោតទាំងអស់គឺនៅមានកម្រិត។

ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពអាចជួយសម្របសម្រួលនូវការការទំនាក់ទំនង ឬឆ្លើយឆ្លងនេះបានយ៉ាងទូលាយ។ តាមរយៈការទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន ដែលមានការទទួលខុសត្រូវ និងប្រកបដោយវិជ្ជាជីវៈ តំណាងរាស្ត្រអាចបញ្ជូននូវខ្លឹមសារពាក់ព័ន្ធនឹងច្បាប់ក្នុងន័យសាមញ្ញៗ បើទោះជាច្បាប់នោះមានភាពស្មុគស្មាញ ដោយពន្យល់ថាតើនរណាដែលនឹងទទួលនូវផលប៉ះពាល់ដោយច្បាប់នេះ ហើយដោយរបៀបយ៉ាងម៉េច។

ជាមួយគ្នាផងដែរ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក៏បានផ្តល់នូវវេទិកាដល់ប្រជាពលរដ្ឋ ដើម្បីផ្សព្វផ្សាយនូវទស្សនៈរបស់ខ្លួន និងចោទសួរនូវសំណួរនានា។ វេទិកានេះ គឺជាមធ្យោបាយមួយ ដែលតំណាងរាស្ត្រអាចដឹងនូវកង្វល់នានារបស់ប្រជាពលរដ្ឋ ហើយកង្វល់ទាំងនោះអាចត្រូវបានលើកយកជាព័ត៌មានត្រលប់សម្រាប់ដំណើរការកិច្ចពិភាក្សារបស់សភាសម្រាប់ការតាក់តែងច្បាប់ ឬការធ្វើវិសោធនកម្មច្បាប់។[32] ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាព ទាមទារតំណាងរាស្ត្របង្កើននូវការយល់ច្បាស់លាស់នូវបទដ្ឋាន និងការអនុវត្តន៍ក្នុងផ្នែកសារព័ត៌មាន និង បង្កើននូវទំនាក់ទំនងប្រកបដោយផលិតភាព និងផ្តល់ផលប្រយោជន៍ទៅវិញទៅមកជាមួយនឹង អ្នកសារព័ត៌មាន។[33]

---

[32] Dr Jamie 0P. Shea. 1998. *The Role of the Media in a Democratic Society.* Delivered at the NATO Seminar, Sarajevo, Bosnia and Herzegovina. Accessed at: www.nato.int/docu/speech/1998/s980707c.htm

[33] Mark Pearson and Roger Patching. 2008. Government and media relations: A 'spin' through the literature. *Humanities & Social Sciences papers.* Paper 228. http://epublications.bond.edu.au/hss_pubs/228

## ៤.១ ការយល់អំពីអ្វីដែលធ្វើឲ្យអត្ថបទព័ត៌មានមួយ «ល្អ»

នៅក្នុងការជ្រើសរើសអត្ថបទព័ត៌មាន ពោលគឺវិធីសាស្ត្រនៃការបកស្រាយ ឬសរសេរអត្ថបទ អ្នកសារព័ត៌មានបានប្រើប្រាស់ទស្សនៈរបស់អ្នកអានមួយចំនួន។ ការជ្រើសរើសអត្ថបទទាំងនេះផ្អែកលើចំណាប់អារម្មណ៍របស់អ្នកអានថាតើពួកគេចង់បាន ហើយត្រូវការអ្វីសម្រាប់ការអាននេះ។ ប្រសិនបើអ្នកតំណាងរាស្ត្រយល់ពីតម្រូវការរបស់អ្នកអានព័ត៌មាន ពោលគឺអ្វីដែលធ្វើឲ្យអត្ថបទសារព័ត៌មានមួយ «ល្អ» ដែលអ្នកអានចង់អាន អាចអនុញ្ញាតឲ្យទំនាក់-ទំនងរបស់តំណាងរាស្ត្រជាមួយសារធារណៈជនកាន់តែល្អ ដោយធ្វើការជាមួយអ្នកសារព័ត៌មានឲ្យកាន់តែមានប្រសិទ្ធភាព។[34] ជាមួយគ្នាផងដែរ អ្នកសារព័ត៌មានជាញឹកញាប់គឺស្ថិតនៅក្រោមសំពាធក្នុងការស្វែងរកអត្ថបទ «ល្អ» មុនកាលកំណត់ និងជាទូទៅមានការស្វាគមន៍ក្នុងការទទួលយកនូវព័ត៌មានក្នុងទម្រង់ដែលងាយស្រួលដល់ពួកគេក្នុងការប្រើប្រាស់។ ដូច្នេះ ព័ត៌មានពាក់ព័ន្ធនឹងសភាជាច្រើន ជាពិសេសព័ត៌មាននៅក្នុងដំណើរការព្រាង និងពិនិត្យឡើងវិញនូវច្បាប់នានា ដែលពាក់ព័ន្ធខ្លាំងជាមួយនឹងអតិថិជនរបស់អ្នកសារព័ត៌មាននឹងផ្តល់ផលប្រយោជន៍សម្រាប់តំណាងរាស្ត្រផ្ទាល់ខ្លួនផង និងសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចជាសារណៈជនទូទៅដើម្បីឲ្យពួកគាត់ទទួលព័ត៌មានដែលមានភាពពេញលេញ និងត្រឹមត្រូវ។[35]

ស្រដៀងគ្នានេះដែរ ការយល់ពីបទដ្ឋានសារព័ត៌មានផ្សេងៗទៀត អាចគាំទ្រដល់ដំណើរការផ្សព្វផ្សាយព័ត៌មាន។ ឧទាហរណ៍៖

– ការដឹងពីតម្រូវការឲ្យមានការដកស្រង់នូវសំដីពីអ្នកពាក់ព័ន្ធ សម្រាប់ការសរសេរអត្ថបទ
– ការប្រើប្រាស់ភាសា «សាមញ្ញ» សម្រាប់បញ្ហាដែលស្មុគស្មាញ និង
– ការបំពេញនូវគ្រប់មាតិកាទាំងអស់មុនកាលកំណត់

ទាំងនេះពិតជាអាចជួយបានច្រើន។[36]

---

[34] Amada Barry. 2002. *PR Power: Inside Secrets from the World of Spin*
[35] National Democratic Institute for International Affairs. 2008. *Constituent Relations: A Guide to Best Practices*
[36] See, for instance, *The News Manual* website: www.thenewsmanual.net

## ៤.២ ដោះស្រាយការសម្ភាសន៍តាមប្រព័ន្ធសារព័ត៌មាន ដោយឆ្លើយនឹងសំណួរពិបាកៗ និង ដោះស្រាយវិបត្តិផ្សេងៗ

ការសម្ភាសន៍គ្រប់ប្រភេទ ដូចជាការបន្តផ្ទាល់តាមវិទ្យុ ឬទូរទស្សន៍ ឬការត្រៀមរៀបចំសម្រាប់ការសរសេរអត្ថបទ គឺជាតួនាទីរបស់អ្នកសារព័ត៌មានក្នុងការសួរសំណួរ ដែលគេគិតថាអតិថិជនរបស់គេចង់សួរដែរ។ នេះមានន័យថាពួកគេគឺជាតំណាងប្រជាពលរដ្ឋ និងចោទសួរសំណួរក្នុងនាមប្រជាពលរដ្ឋ។ ជួនកាល ប្រធានបទដែលត្រូវសម្ភាសន៍ត្រូវបានព្រមព្រៀងគ្នាជាមុន រវាងអ្នកសារព័ត៌មាន និងតំណាងរាស្ត្រ។ ប៉ុន្តែទោះបីជាការសម្ភាសន៍គ្មានការព្រម-ព្រៀងមុនក៏ដោយ ការយល់ដឹងអំពីការអនុវត្តន៍ និងបទដ្ឋានសារព័ត៌មាន ជាពិសេសអំពីលក្ខណៈសារព័ត៌មាន និងអតិថិជន អាចជួយតំណាងរាស្ត្រកំណត់បានប្រធានបទ ឬសំណួរដែលត្រូវចោទសួរ និងបានត្រៀមខ្លួនរៀបចំទុកជាមុន។[37]

ក្នុងពេលជាមួយគ្នាផងដែរ ជាពិសេសក្នុងករណីសម្ភាសន៍តាមទូរទស្សន៍ ឥរិយាបទ និងអាកប្បកិរិយារបស់អ្នកដែលត្រូវបានគេសម្ភាសន៍អាចជះឥទ្ធិពលដល់ចំណាប់អារម្មណ៍របស់ទស្សនិជន ឬអ្នកតាមដានសារព័ត៌មាន។ ការយល់ដឹងពីចំណុចទាំងនេះអាចជួយបង្កើននូវចំណាប់អារម្មណ៍ដែលថាអ្នកដែលត្រូវបានគេសម្ភាសមាន វិជ្ជាជីវៈ និងគួឲ្យគោរព។[38]

ស្រដៀងគ្នានេះដែរ មធ្យោបាយដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយនូវសំណួរពិបាកៗជាពិសេសពេលមានហានិភ័យអ្វីមួយ អាចជួយរក្សានូវកិត្យានុភាពវិជ្ជាជីវៈ និងរក្សាបាននូវជំនឿពីសាធារណៈជន។[39] ប្រវត្តិថ្មីៗនេះបានផ្តល់នូវឧទាហរណ៍ជាច្រើន ដែលអ្នកត្រូវបានគេសម្ភាស មិនត្រឹមតែបានផ្តល់បទសម្ភាសនោះទេ ថែមទាំងឆ្លៀតឱកាសនេះ ដើម្បីប្រើប្រាស់បទសម្ភាសន៍ធ្វើជាឧបករណ៍ដើម្បីបម្រើផលប្រយោជន៍របស់ពួកគេដូចជា ធ្វើការកាត់បន្ថយការភ័យខ្លាចរបស់សាធារណៈជន ឬធ្វើការផ្តោតសំខាន់ទៅលើផែនការល្អៗរបស់ពួកគេ សម្រាប់ដោះស្រាយហានិភ័យនោះ ឬធ្វើការទប់ស្កាត់នូវហានិភ័យកើតឡើងជាថ្មីម្តងទៀតផងដែរ។[40] ប៉ុន្តែក្នុងពេលជាមួយគ្នានេះដែរ តំណាងរាស្ត្រមានផលប្រយោជន៍ពីការយល់ដឹងយ៉ាងច្បាស់ថាសកម្មជន និងក្រុមអ្នកបញ្ចុះបញ្ចូលមានឥទ្ធិពលពី

---

[37] Chris Rose. 2005. *How to Win Campaigns: 100 steps to success.* P133
[38] Paul Richards. 2004. *How to Win an Election.*pp142
[39] CIPR Skills Guide (undated). *Crisis and Risk Management.*
[40] Jessica Hullinger (undated). *Inside a PR disaster.* www.fastcompany.com/304852/lessons-leqarned/inside-a-pr-disaster

មតិសាធារណៈ។[41] ជាការពិតណាស់ សម័យថ្មីដែលប្រើប្រាស់ប្រពន្ធ័អ៊ិនធឺណែតបាននាំមកនូវការបង្កើតសហគមន៍ព័ត៌មានវិទ្យាដែលរួមគ្នាក្នុងការដាក់គំនាប ដើម្បីបញ្ចប់នូវអ្វីដែលពួកគេយល់ឃើញថាជាការរំលោភបំពានសិទ្ធិមនុស្ស ឬភាពអយុត្តិធម៌ផ្សេងៗទៀត ឬក៏ការគំរាមកំហែងផ្នែកបរិស្ថាន។ ឧទាហរណ៍ រួមមាន ក្រុម Avaaz ដែលតាមរបាយការណ៍មានសមាជិកចំនួន ៣០លាននាក់ ទូទាំងពិភពលោកក្នុងឆ្នាំ ២០១៣ ដែលមានឥទ្ធិពលយ៉ាងខ្លាំងលើមតិសាធារណៈជន[42] រួមទាំងអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) និងអង្គការ UK-focused 38 Degrees។ អត្ថិភាព និងអំណាចនៃសហគមន៍ព័ត៌មានវិទ្យានេះ បានពង្រឹងនូវតួនាទីសម្រាប់គ្រប់តំណាងរាស្ត្រ ក្នុងការធានាថាប្រជាពលរដ្ឋនៃប្រទេសរបស់ខ្លួនត្រូវបានទទួលព័ត៌មានបានស័ក្តិសម និងជម្រុញឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការប្រជាធិបតេយ្យ ដែលធ្វើឲ្យពួកគេយល់ និងគាំទ្រជំហររបស់សភាលើបញ្ហាមួយចំនួន។

## ៥. សេចក្តីសន្និដ្ឋាន

ព្រឹទ្ធសភាកម្ពុជាបានឈាននូវជំហានដ៏សំខាន់មួយក្នុងការកែលម្អលើការបើកចំហព័ត៌មាន អំពីសកម្មភាពរបស់សភា៖ ដូចជា ការបង្កើតនូវអ្នកនាំពាក្យ និងការិយាល័យទំនាក់ទំនងសាធារណៈនៃព្រឹទ្ធសភា ដោយទទួលស្គាល់ថាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគឺជាមធ្យោបាយដ៏សំខាន់មួយក្នុងការបញ្ជូនព័ត៌មានទៅកាន់ប្រជាពលរដ្ឋខ្មែរពីការងារសំខាន់ៗដែលធ្វើឡើងដោយព្រឹទ្ធសភា។

ព្រមជាមួយនឹងការមានការិយាល័យទាំងនេះ តម្រូវការនាពេលបច្ចុប្បន្ននេះគឺការជំរុញឲ្យអ្នកបណ្តាញព័ត៌មានបានដឹងកាន់តែច្បាស់អំពីសេវាដែលខ្លួនត្រូវផ្តល់ ដោយយល់ឲ្យច្បាស់ពីតម្រូវការរបស់សមាជិកសភា និងអ្នកសារព័ត៌មានដើម្បីធ្វើឲ្យព័ត៌មានកាន់តែឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេតែម្តង។ ដូច្នេះតាមរយៈការផ្តល់ព័ត៌មានទៀងទាត់នេះ តំណាងរាស្ត្រអាចពង្រឹងតួនាទីភាពជាតំណាងក្នុងការទំនាក់ទំនង ឬឆ្លើយឆ្លងជាមួយប្រជាពលរដ្ឋមានភាពស្វាហាប់ជាងមុន និងជម្រុញដំណើរការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

---

[41] For instance, Beth Corning (in *Accountancy*, March 1999 – *Great Reputations: A PR disaster could cost your corporation dearly)* and Robin Grove-White (in the *New Statesman*, 20 June 1997 – *Brent Spar rewrote the rules)* both outline the cost to a number of major companies that failed to handle a `crisis' effectively

[42] Carole Cadwalladr. 17 November 2013. Inside Avaaz – can online activism really change the world? http://www.theguardian.com/technology/2013/nov/17/avaaz-online-activism-can-it-change-the-world

ទាំងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីសារព័ត៌មានឆ្នាំ ១៩៩៥ បានទទួលស្គាល់នូវសារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងការផ្សារភ្ជាប់រាជរដ្ឋាភិបាលជាមួយនឹងប្រជាពលរដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ បទពិសោធន៍នៃបណ្តាប្រទេសផ្សេងៗទៀតបានផ្តល់នូវឧទាហរណ៍ជាច្រើនដែលបង្ហាញថា៖

- ការធានាថាតំណាងរាស្ត្រ និងអ្នកសារព័ត៌មានយល់នូវតួនាទី
- ការអនុវត្តការងារក្នុងទំនាក់ទំនងគ្នាទៅវិញទៅមក
- ការយល់ឲ្យបានច្បាស់អំពីការទទួលខុសត្រូវនូវតួនាទីរបស់ពួកគេជាអ្នកផ្តល់នូវព័ត៌មានសំខាន់ៗ និងការកសាងនូវទំនាក់ទំនងជាវិជ្ជមានដែលផ្តល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក។

ទាមទារនូវពេលវេលា និងការប្រឹងប្រែង រួមទាំងការអភិវឌ្ឍន៍នូវជំនាញវិជ្ជាជីវៈ និងវិធីសាស្រ្តនានា។

ទោះបីជាយ៉ាងណាក៏ដោយ ដូចឯកសារនេះបានបង្ហាញជូន ប្រសិនបើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសភា មានការអភិវឌ្ឍន៍នូវសក្តានុពលនៃប្រព័ន្ធសារព័ត៌មាន ដើម្បីផ្តល់ដល់ប្រជាពលរដ្ឋនូវវេទិកាក្នុងការទាក់ទង ឬឆ្លើយឆ្លងដ៏មានតម្លៃមួយ ពេលនោះនឹងមានមធ្យោបាយដែលអាចសម្រេចបាននូវគោលដៅទាំងនោះ។ ការយល់ឲ្យកាន់តែច្បាស់ ការកសាងនូវជំនាញតាមរយៈការអនុវត្ត និងចំណេះដឹង ហើយការបង្កើតដំណើរការ និងយន្តការ អាចជួយបានច្រើនក្នុងការឆ្ពោះទៅសម្រេចបាននូវឧត្តមគតិនេះ។

# ឯកសារយោង

Aaronovitch, David. 7 May 2002. *The media column: The lobby system poisons political journalism.* Accessed 14 September 2015. www.independent.co.uk/news/media/the-media-column-the-lobby-system-poisons-political-journalism-650494.html

Asian Forum for Human Rights and Development (FORUM-ASIA). December 2005. *Freedom of Expression and the Media in Thailand.* London: Article 19.

Barry, Amanda. 2002. *PR Power: Inside Secrets from the World of Spin.* London: Virgin Books.

BBC Media Action. August 2002. *Country Case Study: Cambodia. Support to media where media freedoms and rights are constrained.* London: BBC Media Action.

Cadwalladr, Carole. 17 November 2013*. Inside Avaaz – can online activism really change the world?* Accessed 20 August 2015. http://www.theguardian.com/technology/2013/nov/17/avaaz-online-activism-can-it-change-the-world.

Cambodian Center for Independent Media. 2014. *Challenges for Independent Media 2014*. Phnom Penh: CCIM.

Centre for European Studies. Undated. *Social Media – the New Power of Political Influence.* Accessed 15 September 2015. http://www.martenscentre.eu/sites/default/files/publication-files/social-media-and-politics-power-political-influence.pdf.

Chartered Institute of Public Relations. CIPR Skills Guide (undated). *Crisis and Risk Management.*

Chartered Institute of Public Relations. CIPR Skills Guide (undated). *Writing Great Speeches.*

Corner, Adam and Alex Randall. 2011. Selling climate change? The limitations of social marketing as a strategy for climate change public engagement. *Global Environment Change*. 21. 1005-1014.

Curran, James and Myung-Jin Park (eds.). 2000. *De-Westernizing Media Studies.* Abingdon: Routledge.

General Secretariat of the Senate. 2014. *Study on the Strategic Framework and Activity Plan for 10 Years of Capacity Strengthening for the Cambodian Senate (2014-2024)*. Phnom Penh: General Secretariat of the Senate.

General Secretariat of the Senate. 2014. *The Study on the Ten-Year Perspective of the General Secretariat of the Senate (2014-2024).*Phnom Penh: General Secretariat of the Senate.

Hastings, Gerald and Laura McDermott. 2006. Putting social marketing into practice. *BMJ May 20; 332(7551): 1210-1212.*

Howell, Katy. 2012. An Introduction to Social Media. In: Stephen Waddington (ed.) *Share This: The Social Media Handbook for Professionals.* Pp4. Chartered Institute of Public Relations. Chichester: John Wiley & Sons Ltd.

Hullinger, Jessica. (undated). *Inside a PR disaster.* Accessed August 20 2015.
www.fastcompany.com/304852/lessons-leqarned/inside-a-pr-disaster.

International Council for Local Environmental Initiatives (ICLEI) Resource Guide 2009. *Outreach and Communications.* Accessed August 20 2015. www.usclimatenetwork.org/resource-database/Outreach and Communications Guide.pdf.

Keating, Joshua. June 7, 2010. *Can the White House Revoke a Reporter's Credentials?* Foreign Policy. Accessed 14 September 2015. foreignpolicy.com/2010/06/07/can-the-white-house-revoke-a-reporters-credentials/.

Lacey, Alex. 2012. Twitter: The Unstoppable Rise of Microblogging. In: Stephen Waddington (ed.) *Share This: The Social Media Handbook for Professionals.* P71. Chartered Institute of Public Relations. Chichester: John Wiley & Sons Ltd.

McQuail, Denis. 2010. *McQuail's Mass Communication Theory(6th Edition).* London: Sage.

National Democratic Institute for International Affairs. 2008. *Constituent Relations: A Guide to Best Practices.* Washington: NDI.

Pearson, Mark and Roger Patching. 2008. Government and media relations: A 'spin' through the literature. *Humanities & Social Sciences Papers.* Paper 228. Accessed August 20 2015.
http://epublications.bond.edu.au/hss_pubs/228.

Proctor, Tony. 2007. *Public Sector Marketing.* London: Prentice Hall.

Richards, Paul. 2004. *How to Win an Election .*London: Methuen Publishing Limited.

Rose, Chris. 2005. *How to Win Campaigns: 100 steps to success.* London: Earthscan.

Schmitt, Jeff. 2013. *10 Keys to Writing a Speech*. Accessed August 20 2015.
http://www.forbes.com/sites/jeffschmitt/2013/07/16/10-keys-to-writing-a-speech/.

Seiffert, Jeanette. 3 July 2015. *Cambodia using Facebook for women's rights*. Accessed August 20 2015. www.dw.com/en/cambodia-using-facebook-for-womens-rights/a-18558528.

Senate Spokesman Secretariat. 2014. Structure and Role of Senate Spokesman Secretariat.

Shea, Jamie O.P. 1998. *The Role of the Media in a Democratic Society.* Delivered at the NATO Seminar, Sarajevo, Bosnia and Herzegovina. Accessed August 20 2015: www.nato.int/docu/speech/1998/s980707c.htm.

Shwab, Nikki. 2008. In Obama-McCain Race, YouTube Became a Serious Battleground for Presidential Politics. Accessed August 20 2015. http://www.usnews.com/news/campaign-2008/articles/2008/11/07/in-obama-mccain-race-youtube-became-a-serious-battleground-for-presidential-politics.

The Hansard Society. 2010. *Lessons from Abroad: How Parliaments Around the World Engage with their Public. A report from the Group on Information for the Public, UK Parliament*. London: The Hansard Society.

The UK Government. *Government Communication Plan 2015/2016.* Accessed September 3 2015. https://communication.cabinetoffice.gov.uk/government-comms-plan/wp-content/uploads/2015/07/GCS-Government-Communications-Plan-1516.pdf.

UK Government Communications Service. *Writing a Communication Strategy*. Accessed September 3 2015. https://gcn.civilservice.gov.uk/wp-content/uploads/2014/04/Writing-a-communication-strategy-GCS-Guide.pdf.

Williamson, Andy. 2009. *MPs Online: Connecting with Constituents.* London: Hansard Society.

Williamson, Andy. 2013. *Social Media Guidelines for Parliaments.* Inter-Parliamentary Union. Accessed August 20 2015. www.ipu.org/PDF/publications/SMG2013EN.pdf.